# សេចក្តីថ្លែងការណ៍
# អ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា

នៅថ្ងៃទី ១៦ កញ្ញា ឆ្នាំ ២០០៨ កាសែត «បាងកកប៉ុស» របស់ថៃ បានចេញផ្សាយនៅអត្ថបទមួយដោយបានលើកឡើងថា សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានលើកថាប្រទេសថៃ «គួរពិចារណាស្ម័គ្រចិត្តបោះបង់ជាបណ្តោះអាសន្ននូវតួនាទីជាប្រធាន [សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ហៅកាត់ថា អាស៊ាន].... ហើយថៃគួរតែផ្ទេរតួនាទីប្រធាននេះទៅប្រទេស សង្ហ៊ីបុរី រឺ ប្រទេសវៀតណាមវិញ» ហើយកាសែត «បាងកកប៉ុស» បានធ្វើអត្ថាធិប្បាយថា ការធ្វើអត្ថាធិប្បាយរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុនសែននេះ ជាការ «មិនធម្មតា» (Unusual) ដោយថាជាធម្មតាសមាជិកអាស៊ាន «រមែងចៀសវាងមិនធ្វើអត្ថាធិប្បាយលើបញ្ហាផ្ទៃក្នុងរបស់សមាជិកអាស៊ានឯទៀតឡើយ» ។

អ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជាសូមធ្វើការបញ្ជាក់ថា នៅក្នុងបទសំភាសន៍ជាមួយអ្នកកាសែតក្រោយពីពេលជួបជាមួយឯកឧត្តម អនុរដ្ឋមន្ត្រី ការបរទេសអាមេរិច និង ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់ជំនួយរបស់សហរដ្ឋអាមេរិចមក សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុនសែន** មិនដែលប្រើពាក្យ «**គួរតែ**» រឺ «**ត្រូវតែ**» រឺ ពាក្យអត្ថាធិប្បាយណាមួយដែលប៉ះពាល់ដល់បញ្ហាតួនាទីជាប្រធានអាស៊ានរបស់ប្រទេសថៃ នោះឡើយ សម្តេចគ្រាន់តែលើកពីកង្វល់ពីលទ្ធភាពដែលអាចកើតមានជាយថាហេតុដែលការប្រជុំកំពូលអាស៊ាន មិនអាចធ្វើទៅបាននៅប្រទេសថៃ ហើយតើគេនឹងទៅធ្វើកិច្ចប្រជុំនៅទីណាបានតែប៉ុននោះ ។ អ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជាសូមលើកឡើងជាថ្មីនូវគោលជំហរឥតប្រែប្រួលរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការគោរពអធិបតេយភាព និង ឯករាជភាពរបស់ប្រទេសទាំងអស់ទោះជានៅក្នុង រឺ ក្រៅអាស៊ានក្តី ប៉ុន្តែដូចដែលសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុនសែន** បានបញ្ជាក់យ៉ាងច្បាស់នៅក្នុងការផ្តល់សំភាសន៍កាលពីល្ងាចថ្ងៃទី ១៥ កន្លងនេះមកហើយថា អ្វីដែលសម្តេចបានលើកពីកង្វល់នេះ«មិនមែនទាក់ទិនតែមុខមាត់របស់ប្រទេសថៃប៉ុននោះទេ តែគឺទាក់ទិននឹងសមាជិកអាស៊ានទាំងអស់» តែប៉ុននោះ ។ មកដល់បច្ចុប្បន្ននេះ បំនងប្រាថ្នារបស់រាជរដ្ឋភិបាលគឺគ្មានអ្វីក្រៅពីចង់ឃើញសភាពការណ៍ របស់ប្រទេសថៃវិលត្រលប់ទៅរកប្រក្រតីភាពវិញដើម្បីធានាសន្តិភាព និង សុខដុមរមនាក្នុងសង្គមជាតិថៃផង ក្នុងសហគមន៍អាស៊ាននេះផងនោះឡើយ ។

***ភ្នំពេញ, ថ្ងៃទី ១៦ កញ្ញា ឆ្នាំ ២០០៨***

រក្សាសិទ្ធគ្រប់យ៉ាងដោយ ក្រសួងព័ត៌មាន